# ការសំភាសន៍របស់លោកយាយ យាយអុឹ

កៈ អ្នកដែរសំភាសន៍គេមាន ជាង ស៊ីអ៊ារ ខៈ អ្នកដែរអោយគេសំភាសន៍ យាយអុឹ

## <u>ការសង្ខេបប្រវត្តិរបស់ លោកយាយ យាយអុឹ</u>

លោកយាយ យាយអុឹ មានអាយុ87ឆ្នាំ នៅក្នុងឆ្នាំ2018 លោកយាយ យាយអុឹ មានភេទស្រី លោកយាយ យាយអុឹ មានទីលំនៅបច្ចុប្បន្ននៅភូមិស្ទឹងជ្រៅ ឃុំផ្សារដើមមាន នៅស្រុកតាខ្មៅ ខេត្តកណ្តាល។

កៈ ចឹងជាដំបូងខ្ញុំអរគុណយាយដែរបានអោយខ្ញុំពិភាក្សាពីប្រវត្តិរបស់យាយ ហើយការសំភាសន៍មួយនេះត្រូវបានរៀបចំដោយសកលវិទ្យាល័យមួយដែរនៅអាមេរិចដែរមានឈ្មោះថាBYU
ហើយដោយសារតែសកលវិទ្យាមានគោលបំណងចង់រក្សាពីប្រវត្តិរបស់ប្រជាជនខ្មែរ ដើម្បីអោយពួកគាត់ បានស្គាល់ពីប្រវត្តិរបស់ឪពុកម្តាយនឹង ប្រវត្តិរបស់ដូនតាចឹងនៅពេលដែរខ្ញុំបានសំភាសន៍យាយ
ហើយនឹងខ្ញុំនឹងដាក់ការសំភាសន៍ទាំងអស់នឹងទៅក្នុងវេបសាយរបស់សាលាដែរមានឈ្មោះថា www.cambodianoralhistories.byu.edu
ចឹងសំរាប់យាយយល់ព្រមដើម្បីអោយខ្ញុំដាក់ការសំភាសន៍ មួយនឹងទៅក្នុងវេបសាយរបស់សាលាដែរទេយាយ?

ខៈ ចា៎!!នឹង

កៈ បាទយាយបាទ?

ខៈ និយាយពីប្រវត្តិនិងយ៉ាងម៉េច?

កៈ ប្រវត្តិពីដើមពីក្មេងចឹងហាសយាយ
បាទចឹងគ្រាន់តែខ្ញុំសួរយាយហើយយាយប្រាប់តាមអ្វីដែរខ្ញុំសួរចឹងហាសយាយ?

ខៈ ចា៎!!នឹងហើយអត់អីទេ

កៈ បាទអុឹបាទចឹងសំរាប់ខ្ញុំជាអ្នកសំភាសន៍អុឹខ្ញុំមានឈ្មោះថា ជាង ស៊ីអ៊ារ ហើយថ្ងៃខែដែរខ្ញុំបានសំភាសន៍អុឹគឺនៅថ្ងៃទី5ខែ4 ឆ្នាំ2018
ហើយការសំភាសន៍ទាំងអស់នេះត្រូវបានធ្វើឡើងនៅភូមិ នឹងភូមិអីគេមិញយាយ?

ខ៖ នៅនឹងសព្វថ្ងៃនឹងហោស?

ក៖ បាទយាយាបាទ?

ខ៖ នៅភូមិស្នឹងជ្រៅ

ក៖ ចុះឃុំអីគេដែរយាយ?

ខ៖ ភូមិស្នឹងជ្រៅ ឃុំផ្សារដើមមាន

ក៖ ចុះឃុំផ្សារដើមមាន ចុះស្រុកអីគេដែរ?

ខ៖ នៅស្រុកតាខ្មៅនឹង ខេត្តកណ្ដាល

ក៖ អូ្!!បាទយាយ ចុះសព្វថ្ងៃនឹងយាយមានឈ្មោះពេញនឹងឈ្មោះអីគេដែរទៅយាយ?

ខ៖ មានឈ្មោះអ៊ុំចឹងតែម្ដងនឹងឈ្មោះអ៊ុំគេហៅតែយាយអ៊ុំៗនឹងតែម្ដងនឹង

ក៖ ប៉ុន្តែត្រកូលនឹងអត់មានទេ?

ខ៖ អត់អត់មានដូរផ្លាស់អីគេទេ

ក៖ អូ្!!ចុះឈ្មោះអីផ្សេងនឹងក៏អត់មានដែរណាអ៊ុំ?

ខ៖ អត់អត់ដឹងថាប្រែប្រួលថាម៉េចទេ

ក៖ អូ្!!បាទយាយបាទ?

ខ៖ លឺតែគេថាចឹងហាស

ក៖ ចុះកាលពីក្មេងនឹងមានធ្លាប់មាននរណាហៅឈ្មោះយាយអីផ្សេងទៀតទេយាយ?

ខ៖ អត់អត់ទេនឹងហាស

ក៖ អូ្!!បាទចុះយាយសព្វថ្ងៃយាយអាយុប៉ុន្មានដែរយាយ?

ខ៖ ខ្ញុំអាយុ87ឆ្នាំនឹង

ក៖ យាយអាយុ87ឆ្នាំណយាយ ចុះយាយកើតនៅថ្ងៃខែឆ្នាំណាដែរយាយមានចងចាំទេ?

ខ៖ រឿងថ្ងៃខែអត់ចងចាំទេតែលឺចាស់ៗថាខ្ញុំឆ្នាំរ៉ៃក

ក៖  ចឹងយាយឆ្នាំវែក ប៉ុន្តែយាយនៅឆ្នាំណាក៏យាយមិនដឹងដែរ?

ខ៖  អត់មានដឹងទេ

ក៖  ចឹងយាយកើតនៅឆ្នាំ1931ហាសយាយ?

ខ៖  អើរនឹងហោស

ក៖  ចុះសំរាប់យាយកើតនៅណាដែរយាយមានដឹងទេ?

ខ៖  ខ្ញុំកើតនៅខេត្តព្រៃវែង

ក៖  កើតនៅព្រៃវែងប៉ុន្តែភូមិអីគេដែរយាយ?

ខ៖  ឃុំជ្រៃ

ក៖  ចុះភូមិវិញយាយ?

ខ៖  ភូមិនឹងគេហៅភូមិចំបក

ក៖  នៅភូមិចំបក ឃុំជ្រៃ ចុះស្រុកអីគេដែរយាយ?

ខ៖  ស្រុកឃុំជ្រៃនឹងព្រៃវែងនឹង អូស្រុកកំពង់ត្របែក

ក៖  ចឹងនៅស្រុកកំពង់ត្របែកនៅខេត្តព្រៃវែងណាយាយ?

ខ៖  ចា៎!!នឹងហើយចឹង

ក៖  ចុះយាយមានបងប្អូនចំនួនប៉ុន្មាននាក់ដែរយាយ?

ខ៖  ខ្ញុំមានបងប្អូន4នាក់

ក៖  ចុះយាយជាកូនទីប៉ុន្មានដែរយាយ?

ខ៖  ខ្ញុំជាកូនទី3

ក៖  ចុះមានស្រីប៉ុន្មាននាក់ នឹងប្រុសប៉ុន្មាននាក់ដែរ?

ខ៖  មានស្រី2នាក់ ហើយនឹងប្រុស2នាក់ ឥឡូវនឹងស្លាប់អស់ហើយគ្មានសល់ទេ

ក៖  ចឹងនៅសល់តែយាយមួយទេណាយាយ?

ខ៖ ចាំ!!នឹងហើយ

ក៖ ចុះបងប្អូនរបស់យាយនឹងមានឈ្មោះអីគេដែរយាយ?

ខ៖ មានឈ្មោះសេង

ក៖ នឹងបងធំណាយាយ?

ខ៖ ចាំ!!នឹងហើយ

ក៖ ចុះបងទី2វិញយាយ?

ខ៖ បងទី2នឹងមានឈ្មោះសុំស្លាប់អស់ហើយនឹង

ក៖ ហើយចុះប្អូនពៅវិញយាយ?

ខ៖ ហើយខ្ញុំមានឈ្មោះយាយអ៊ុំ ហើយប្អូនរបស់ខ្ញុំនឹងាមានឈ្មោះយាយគារ

ក៖ ចឹងគាត់ឈ្មោះគារណាយាយ ចុះយាយធ្លាប់មានអនុស្សាវរីយ៍អីកាលពីនៅក្មេងៗ ធ្លាប់បានលេងអីជាមួយគ្នាដែរទេ?

ខ៖ អើយនៅស្រុកស្រែនឹងគ្មានបានលេងអីទេនៅមើលតែគោនឹងហាស

ក៖ យាយនៅមើលគោណាយាយ ចុះលេងបិទពួនអីយាយធ្លាប់បានលេងដែរទេ?

ខ៖ ទេខ្ជិលលេងណាស់នៅតែឈរមើលគេនឹងហាស

ក៖ អូ៎!!បាទយាយបាទ?

ខ៖ នឹងហើយខ្ជិលណាស់

ក៖ ចុះយាយចូលចិត្តលេងអីជាមួយបងប្អូនរបស់យាយដែរ?

ខ៖ ថាអត់ទេធុញមួយអាយសនឹង

ក៖ ចឹងហោសយាយហោសជាមួយបងប្អូនដែរ?

ខ៖ គេលេងអីលេងទៅខ្ជិលរវល់នឹងហាស

ក៖ អូ៎!!បាទយាយបាទ ចុះម្តាយរបស់យាយនឹងគាត់មានឈ្មោះអីគេដែរយាយ?

ខ៖ គាត់មានឈ្មោះយាយសោ

ក៖ គាត់មានឈ្មោះយាយសោ ចុះឪពុករបស់យាយនឹងគាត់មានឈ្មោះអីគេដែរយាយ?

ខ៖ គាត់មានឈ្មោះហិន

ក៖ គាត់មានឈ្មោះតាហិន ហោសយាយ ចុះម្ដាយរបស់យាយគាត?

ខ៖ គាត់ាមនឈ្មោះសោ

ក៖ គាត់ឈ្មោះសោប៉ុន្តែគាត់កើតនៅណាដែរយាយមានដឹងអត់?

ខ៖ គាត់កើតនៅភូមិជាមួយគ្នានឹងនៅព្រៃវែងនឹង

ក៖ ប៉ុន្តែឪពុករបស់យាយវិញ?

ខ៖ ឪពុករបស់ខ្ញុំអីនឹងនៅជិតៗគ្នានឹងហាស

ក៖ អូ៎!!បាទយាយបាទ ចុះឪពុករបស់យាយគាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរយាយ?

ខ៖ គាត់មានធ្វើអីគាត់បួសធ្វើលោកសង្ឃ គាត់សឹកមកគាត់ការជាមួយម៉ែរបស់ខ្ញុំនឹង

ក៖ អើរកើតអីបានជាគាត់បួសហាសយាយមានដឹងអត់?

ខ៖
ខ្ញុំមិនដឹងដែរនឹងនៅស្រុកពីដើមនឹងហាសពីដើមនឹងបើនៅក៏100ឆ្នាំដែរអាយុជាង100ឆ្នាំបាត់ទៅ

ក៖ បាទត្រូវហើយយាយចុះគាត់កាចរឺមួយក៏ស្លូតដែរយាយ?

ខ៖ សុទ្ធតែស្លូតហើយនឹងមិនដែរបានទៅធ្វើអីនរណាគេផងនឹង

ក៖ ចុះម្ដាយរបស់យាយកាត់មានឈ្មោះអីគេ?

ខ៖ គាត់ឈ្មោះយាយស៊ននឹង

ក៖ គាត់ធ្វើអីគេដែរសំរាប់ចិញ្ចឹមជីវិតដែរយាយ?

ខ៖ គាត់លក់ដូរត្បូងចេកអីចឹងទៅណាស់

កៈ អូ៎!!បាទយាយបាទ ចុះគាត់ស្លូតរឺមួយក៏កាចដែរយាយ?

ខៈ គាត់ស្លូតណាស់កាត់ស្លាប់បាត់ហើយនឹង

កៈ ប៉ុន្តែយាយមានចងចាំអនុស្សាវរីយ៍ជាមួយឪពុកម្ដាយរបស់យាយ
ថាមានធ្លាប់បានធ្វើអីគេខ្លះដែរទេយាយ?

ខៈ អូស!ស្លាប់តាំងខ្ញុំនៅអាយុ8ឆ្នាំហោស

កៈ បាទប៉ុន្តែពីមុនយាយអាយុ8ឆ្នាំហាសយាយមានធ្លាប់បានធ្វើអីគេដែរជាមួយតានឹង?

ខៈ គ្មានបានធ្វើអីទេដើរតែលេងទេ

កៈ អូ៎!!ចឹងដើរតែលេងទេហោសយាយ?

ខៈ នឹងហើយដើរតែលេងនឹងលេងៗឈ្លោះគេ

កៈ ម៉េចចឹងយាយម៉េចបានឈ្លោះគ្នាចឹងយាយ?

ខៈ វាដណ្ដឹងកៅអីគ្នាអង្គុយអីចឹងទៅ

កៈ បាទយាយបាទ ចុះយាយគាត់មានធ្លាប់ប្រាប់ពីប្រវត្តិរបស់គាត់ទៅយាយទេ?

ខៈ
អត់ទេមិនដឹងមាននិយាយអីគេទេនឹងគាត់ស្លាប់អស់រលីងខ្ញុំនៅក្មេងនឹងមិនទាន់បានដឹងអីផងនឹង

កៈ ឪពុករបស់យាយនឹងក៏គាត់មិនដែរប្រាប់ដែរណាយាយ?

ខៈ អត់ទេឪពុករបស់ខ្ញុំនឹងបួសធ្វើលោកសង្ឃធ្វើលោកហោស

កៈ អូ៎!!បាទយាយ ចុះសំរាប់យាយតាខាងឪពុកនឹងយាយមានស្គាល់ឈ្មោះគាត់ដែរទេ?

ខៈ ខ្ញុំស្គាល់ទាំងអស់នឹងហាស

កៈ យាយតាខាងឪពុកនឹងគាត់មានឈ្មោះអីគេដែរយាយ?

ខៈ គាត់មានឈ្មោះថាតាតី

កៈ ចុះយាយវិញ?

ខ៖ គាត់មានឈ្មោះយាយសួស

ក៖ ចុះគាត់កើតនៅណាដែរយាយមានដឹងអត់?

ខ៖ គាត់កើតនៅស្រុកកំពង់ត្របែកទាំងអស់នឹងហាស នៅឃុំជ្រៃនឹងហាស

ក៖ ចុះយាយតាខាងម្ដាយវិញយាយ?

ខ៖ នៅជិតគ្នានឹង

ក៖ ប៉ុន្តែពួកគាត់មានឈ្មោះអីគេដែរយាយ?

ខ៖ ឈ្មោះយាយស នឹងម្ដាយគាត់មានឈ្មោះឪពុកគាត់មានឈ្មោះតាខៀវ ប្រពន្ធរបស់គាត់ឈ្មោះយាយមឹង

ក៖ អូ៎!!បាទយាយចុះចឹងគាត់កើតនៅនឹងទាំងអស់គ្នាណយាយ?

ខ៖ ចា៎!!កើតនៅជិតគ្នានឹងហាស

ក៖ អូ៎!!បាទ ចុះយាយមកនៅនឹងយូរនៅយាយ?

ខ៖ ខ្ញុំមកនៅតាំងពីឆ្នាំ1979មកម្ល៉េសនឹង

ក៖ តាំងពីឆ្នាំ1979រហូតមកដល់ឥឡូវនឹងវាអស់39ឆ្នាំណយាយ?

ខ៖ វាជាង30ឆ្នាំហើយនឹង

ក៖ បាទយាយ ចុះយាយមានកូនចៅរឺមួយក៏បងប្អូនណាដែរទៅរស់នៅក្រៅប្រទេសទេយាយ?

ខ៖ អត់មានទេអត់មានសុទ្ធ

ក៖ នៅថៃ វៀតណាមអីក៏អត់មានដែរណយាយ?

ខ៖ អត់មានទេ

ក៖ អូ៎!!បាទយាយ ចុះស្វាមីរបស់យាយនឹងគាត់មានឈ្មោះអីគេដែរយាយ?

ខ៖ គាត់មានឈ្មោះឆេង

កៈ គាត់មានឈ្មោះអីគេឆេងដែរយាយ?

ខៈ គាត់មានឈ្មោះនង ឆេង

កៈ ប៉ុន្តែឥឡូវនឹងគាត់?

ខៈ អើយនៅសុទ្ធតែជាងអាយុ100ឆ្នាំអស់ហើយនឹង

កៈ ប៉ុន្តែគាត់បានស្លាប់បាត់ហើយណាយាយ?

ខៈ គាត់ស្លាប់អស់ហើយនឹង

កៈ អូ៎!!បាទ ចុះនៅពេលដែរយាយរៀបអាពាហ៍ពិពាហ៍នឹងគិតថា យាយជាអ្នករៀបចំដោយចិត្តឯងរឺមួយក៏ឪពុកម្តាយគាត់ជាអ្នករៀបចំអោយដែរយាយ?

ខៈ ទេអានឹងចិត្តឯងទេនឹងគ្មានបានការអីទេ អូសការដែរកុំនិយាយអត់ការតិចតួច

កៈ អូ៎!!បាទយាយប៉ុន្តែយាយការនៅឆ្នាំណាដែរយាយមានចងចាំទេ?

ខៈ ហ៎!!អត់ចងចាំដែរខ្ញុំ ខ្ញុំដឹងតែខ្លួនខ្ញុំចាស់ហើយបានខ្ញុំមានកូននឹង

កៈ អូ៎!!បាទយាយបាទ?

ខៈ ខ្ញុំអាយុ25ឆ្នាំហើយនឹងបានមានកូនហោស

កៈ ចឹងយាយទាល់តែយាយអាយុ25ឆ្នាំបានយាយមានកូនមែនទេយាយ?

ខៈ ចា៎!!នឹងហើយចឹងឥឡូវនឹងកូនរបស់ខ្ញុំនឹងអាយុ60ឆ្នាំជាងហើយនឹង

កៈ ចឹងយាយការអស់63ឆ្នាំហើយណាយាយណា?

ខៈ ចា៎!!នឹងហើយ

កៈ អូ៎!!បាទយាយនៅពេលដែរយាយរៀបអាពាហ៍ពិពាហ៍ជាមួយតានឹងតាអោយជាជំនូនទៅយាយទេ?

ខៈ អោយដែរនឹងអោយតិចតួចនឹងជួយធ្វើផ្ទះធ្វើសំបែងអោយនៅនឹងហាស

កៈ បាទយាយ ហេតុអ៊ីបានជាតាស្រលាញ់យាយ
ហើយគាត់ស្រលាញ់ពេលណាអីយាយមានដឹងទេ?

ខៈ អើរឃើញគាត់ធូរធាមានលុយមានកាក់នឹង

កៈ អូ៎!!បាទយាយ ចុះយាយរៀនភាសាខ្មែរបានល្អប៉ុណ្ណាដែរយាយ?

ខៈ អើយអត់រៀនបានមួយអង្គទេ

កៈ អត់ដែរបានរៀនទេណយាយ?

ខៈ ចាស់ៗៗអត់អោយទៅរៀនទេនឹង អ្នកស្រែគាត់ថាខ្លាចរត់តាមប្រុសនឹង

កៈ អូ៎!!ម៉េចចឹង ម៉េចបានមួយជំនាន់គេគិតចឹងយាយ?

ខៈ ដឹងអីហោសនៅស្រុកស្រែអ្នកស្រែចឹងតើ!!
ខ្ញុំថាគេទៅរៀនច្រើនខ្ញុំទៅរៀនដែរទៅគេមិនអោយទៅរៀនទេ

កៈ អូ៎!!គេខ្លាចយើងរត់តាមគ្នាណយាយ?

ខៈ នឹងហើយចឹង

កៈ អូ៎!!បាទយាយ ចុះចឹងយាយមានចេះភាសាអីផ្សេងដែរទេយាយ?

ខៈ អើយគ្មានចេះអីទេ

កៈ បារាំងអត់ចេះដែរ?

ខៈ អូយ អត់សុទ្ធនឹងហាសគ្មានបានរៀនគ្មានបានសូត្រអីទេ

កៈ បាទយាយបាទ?

ខៈ ប៉ុន្តែថៅអីគេចេះមួយម៉ាត់ពីរម៉ាត់គេរៀននឹងហាស

កៈ ចុះសំរាប់យាយធ្លាប់មានមិត្តភក្តិដែរស្និទ្ធិស្នាលដែរធំធាត់មកជាមួយគ្នាដែរទេយាយ?

ខៈ អត់មានទេ

កៈ បងប្អូនចឹងយាយមានតែបងប្អូនទេណយាយ?

ខ៖
មានតែជីដូនៗៗមួយនឹងមានបងប្អូនបង្កើតណាបើស្លាប់តាំងពីបែកអាពតនឹងមកហើយនឹង

ក៖ ប៉ុន្តែកាលយាយនៅជាមួយជីដូនមួយអីនឹង
គិតថាយាយធ្លាប់លេងអីគេខ្លះដែរជាមួយគាត់ហាសយាយ?

ខ៖ អត់ដែរលេងអីទេខ្ញុំប្រកាន់ខ្លួនណាស់មិនលេងតែម្តងនឹងអោបតែដៃនឹង

ក៖ ម៉េចចឹងយាយប្រកាន់ខ្លួនម្ល៉េសយាយ?

ខ៖ កាលណាចឹងមិនចេះលេងអីទេដឹងតែដេកមើលគោពេលថ្ងៃ

ក៖ អ៊ូ!!ចឹងហោសយាយ?

ខ៖ ចាំ!!នឹងហើយចឹង

ក៖ ចុះយាយគិតថាជីវិតរបស់យាយមានការផ្លាស់ប្តូរអីគេខ្លះដែរទៅយាយ
តាំងពីក្មេងរហូតមកដល់ពេលនេះហាសយាយ?

ខ៖ អត់សោះនឹងហាស

ក៖ ចឹងអត់មានការផ្លាស់ប្តូរអីទេណាយាយ?

ខ៖ ចាំ!!នឹងហាស

ក៖
ចុះយាយតាំងពីក្មេងរហូតមកដល់ពេលនេះនឹងយាយមានធ្លាប់បានធ្វើការងារអីគេខ្លះដែរយាយ?

ខ៖ ខ្ញុំនឹងនៅតែចង្ក្រានឆ្នាំងនឹង

ក៖ ចឹងហោសយាយ?

ខ៖ មិនធ្វើអីទេនៅតែចង្ក្រានឆ្នាំងនឹងហាសមិនធ្វើស្អីគេទេ

ក៖ ហើយនឹងយាយធ្វើស្រែធ្វើអីនយាយ?

ខ៖ នឹងហើយធ្វើចឹង

កះ ចុះយាយធ្លាប់បើកអាជីវកម្មលក់ដូរអីទេយាយ?

ខះ ខ្ញុំអត់សោះហើយនឹងប៉ុន្តែកូនរបស់ខ្ញុំបានវាលក់ប៉ុន្តែឥឡូវនឹងវាស្លាប់បាត់ហើយនឹង

កះ អូ៎!!បាទយាយហេតុអីបានជាកូនយាយស្លាប់ដែរយាយ?

ខះ វាកើតមហារីកនឹង

កះ អូ៎!!ចុះយាយគិតថាយាយមានធ្លាប់ចិញ្ចឹមសត្វទេ ដូចថាចិញ្ចឹមគោ ចិញ្ចឹមមាន់អីហាស?

ខះ អត់ទេធ្លាប់តែចិញ្ចឹមគោនៅស្រុកស្រែពីដើមនឹងជិះតែគោនឹង

កះ ប៉ុន្តែចិញ្ចឹមច្រើនដែរទេយាយ?

ខះ មានចិញ្ចឹមគោមួយនឹមនឹងហាស

កះ អូ៎!!បាទយាយបាទ?

ខះ គេប្រើអោយមើលតែគោនឹង

កះ អូ៎!!មាន់ ទា ជ្រូកអីយាយមិនដែរចិញ្ចឹមទេណាយាយ?

ខះ អត់ដែរទេ

កះ អូ៎!!បាទយាយបាទ?

ខះ ខ្ញុំខ្ជិលតែម្តងនឹងហាស

កះ ចឹងយាយខ្ជិលណាយាយ ចឹងយាយធ្លាប់ទៅធ្វើការងារនៅវាលស្រែដែរណាយាយ?

ខះ ទៅស្រែដកស្ទូងអីនឹងចេះមួយចប់នឹងហាស

កះ អូ៎!!នឹងគេអោយយាយធ្វើណាយាយ?

ខះ ចា៎!!នឹងហើយចឹង

កះ ចុះយាយគិតថាម្ហូបអីដែរយាយចូលចិត្តពិសារដែរយាយ?

ខះ ហោ៎!!ស្អីក៏ចង់ដែរអោយតែមានលុយទិញនឹង

កះ អូ៎!!ប៉ុន្តែចិត្តដែរយាយចង់តែម្តងនឹងម្ហូបដែរយាយចូលចិត្តហាសម្ហូបអីគេដែរយាយ?

ខ៖ មិនដឹងមិនប្រាកដទេនឹងជូនណាមានត្រីងៀតហូបទៅ ជូនណាមានសំលអីហូបចឹងទៅ

ក៖ អូ៎!!បាទយាយបាទ?

ខ៖ មិញបង្គាប់គេអោយទិញត្រីសំលម្ជូរ

ក៖ អូ៎!!ចឹងហោសយាយ?

ខ៖ ចឹងដឹងគេទិញអោយរឺមួយក៏អត់?

ក៖ អូ៎!!បាទយាយបាទ ចុះល្បែងប្រជាប្រិយ៍អីដែរយាយចូលចិត្តលេងតាំងពីក្មេងហាសយាយ?

ខ៖ ទេលេងមិនដែរឈ្នះគេផងនឹង

ក៖ ប៉ុន្តែភាគច្រើននឹងយាយលេងអីគេដែរល្បែងប្រជាប្រិយ៍ហាស?

ខ៖ អត់មានអាលេងប្រលែងលេងសើចអីនឹងខ្ញុំអោបដៃឈរមើលគេបើមិនចឹងទេដេកមើលគេ

ក៖ លក្ខណះចោលឈូង បោះអង្គុញ ទាញព្រាត់អីហាសយាយ?

ខ៖ អើយអត់លេងទេនឹងហាសខ្ញុំធុញណាស់នឹងហាស

ក៖ អូ៎!!យាយអត់ចូលចិត្តលេងទេហោសយាយ?

ខ៖ អត់មានចូលចិត្តទេ

ក៖ ចុះយាយចេះច្រៀងទេយាយ?

ខ៖ អត់សុទ្ធហើយបើសំលេងមើលតែផ្គរលាន់ចឹង

ក៖ ប៉ុន្តែយាយចូលចិត្តស្តាប់បទចំរៀងដែរទេយាយ?

ខ៖ អត់ទេនឹង

ក៖ ប៉ុន្តែយាយចូលចិត្តស្តាប់ធិមហីយាយ?

ខ៖ នឹងហើយស្តាប់ធិមនឹង

កៈ បាទយាយចុះយាយគិតថាមាននរណាម្នាក់?

ខៈ ទេបើគេលេងឆាកកំប្លែងអីក៏មើលគេបន្តិចដែរ

កៈ អូ៎!!មើលនៅក្នុងទូរទស្សន៍អីចឹងហោសយាយ?

ខៈ ចា៎!!នឹងហើយចឹង

កៈ ចុះយាយគិតថាមាននរណាម្នាក់ហាស
នៅក្នុងក្រុមគ្រួសាររបស់យាយចេះលេងឧបករណ៍ភ្លេងដែរទេយាយ?

ខៈ ចៅរបស់ខ្ញុំនឹងលេងភ្លេងពិនពាត

កៈ អូ៎!!លេងភ្លេងពិនពាតលេងនៅណាដែរយាយ?

ខៈ លេងនៅវត្តនឹងហាស

កៈ អូ៎!!គាត់នៅលេងទាល់តែតឡូវនឹងហោសយាយ?

ខៈ ចា៎!!នឹងហើយចឹង

កៈ
ចុះផ្ទះរបស់យាយមានលក្ខណាហាបែបណាដែរយាយតាំងពីក្មេងរហើតមកដល់ពេលនេះហាស?

ខៈ ហើយតែខ្ទមៗនឹងហាសរុះមួយកន្លែងធ្វើមួយកន្លែងចឹងទៅ

កៈ បាទចឹងហោសយាយ?

ខៈ មុនដំបូងតូចចឹងទៅហើយបានរីកធំចឹងទៅណាស់

កៈ អូ៎!!បាទយាយបាទ?

ខៈ គ្មានបានផ្ទះធំទំនុំខ្ពស់នៅទេ

កៈ ចុះនរណាគេជាង្នកជួសជុលខ្ទមផ្ទះនឹងអោយយាយដែរទៅ?

ខៈ កូនរបស់ខ្ញុំមីស្លាប់ទៅនឹង

កៈ អូ៎!!គាត់ជាអ្នកធ្វើហោសយាយ?

ខ៖ បានមីស្លាប់នឹងទៅបានមានហូរហៃនឹង

ក៖ ប៉ុន្តែគាត់ចេះធ្វើផ្ទះមែនយាយ?

ខ៖ ជួលគេនឹង

ក៖ ចឹងអោយលុយគេជួលគេធ្វើណាយាយ?

ខ៖ នឹងហើយចឹង

ក៖ អូ៎!!បាទយាយបាទ?

ខ៖ ធ្វើចឹងៗៗអីខ្ញុំអត់ស្រលាញ់ផងប៉ុន្តែគេធ្វើអោយហើយចេះតែនៅទៅ

ក៖ អូ៎!!បាទយាយបាទ?

ខ៖ ខ្ញុំចង់បានអាមានដំបូលព្រំនឹងហាស

ក៖ អូ៎!!ប៉ុន្តែដោយសារតែយើងមិនសូវមានលុយណាយាយ?

ខ៖ នឹងហើយវាចឹងហើយ

ក៖ ចុះយាយគិតថាគេប្រើឧបករណ៍រឺមួយសំភារះអីសំរាប់ជួសជុលដែរយាយ?

ខ៖ ទេទាល់តែជាងគេអ្នកធ្វើខ្ញុំអត់យកចិត្តទុកដាក់ផង

ក៖ អូ៎!!បាទយាយបាទ
ចុះយាយគិតថាមាននរណាគេមួយនៅក្នុងក្រុមគ្រួសាររបស់យាយនឹងចេះធ្វើផ្ទះទេ?

ខ៖ អត់ទេនឹងខ្ញុំមានចៅតែពីរនាក់នឹងមានកូនតែពីរនាក់
ហើយចៅក៏មានតែពីរនាក់ដែរនឹង

ក៖ ចុះប្តីរបស់យាយពីមុននឹងគាត់ចេះធ្វើទេយាយ?

ខ៖ អត់ទេគាត់ចៅចិនដែរនឹង

ក៖ បាទយាយបាទ?

ខ៖ គាត់អត់មានធ្វើអីទេនឹង

ក៖ ចុះគិតថាជំនាញអីដែរយាយចេះស្ទាត់ជំនាញដែរយាយ?

ខ៖ គាត់ធ្វើជញ្ជួនកប៉ាល់នឹង

ក៖ អូ៎!!ជញ្ជួនកប៉ាល់ហោសយាយ?

ខ៖ ចា៎!!នឹងហើយ

ក៖ ប៉ុន្តែយាយមានចេះជំនាញអីដែរទេយាយ?

ខ៖ អត់ទេស្អីក៏មិនដឹងដែរ ដេរក៏ដេរមិនកើតដែរនឹង

ក៖ ចឹងយាយចេះតែធ្វើស្រែដកស្ទូងទេណាយាយ?

ខ៖ ចា៎!!នឹងហើយចឹងចាំតែដាំបាយអោយគេហូបនឹងហាស

ក៖ អូ៎!!បាទ ចុះឪពុកម្តាយរបស់យាយនឹងធ្លាប់បង្រៀនពីជំនាញអីផ្សេងទៅយាយដែរទេ?

ខ៖ អត់ទេគ្មានបានបង្រៀនអីទាន់បើខ្ញុំអាយុ8ឆ្នាំអីនឹងគាត់ស្លាប់ទៅនឹងហាស

ក៖ ចឹងមានន័យថាវេញវល្លិ៍ កូរស្ករត្នោត ធ្វើផ្តៅ ធ្វើជាកន្ទេល
អីនឹងយាយអត់មានចេះទេណាយាយ?

ខ៖ អត់ៗទេអត់ចេះទេនឹងហាសអូ ចុះធ្វើកន្ទេលស្លឹកត្នោតនឹង

ក៖ អូ៎!!យាយចេះធ្វើហោសយាយ?

ខ៖ ចេះធ្វើស្លឹកត្នោតនឹងចឹមិនចេះ

ក៖ អូ៎!!បាទយាយបាទចឹងយាយចេះធ្វើតែកន្ទេលស្លឹកត្នោតទេណាយាយ?

ខ៖ ចា៎!!ចេះធ្វើតែអានឹង

ក៖ ប៉ុន្តែកាលណុងយាយធ្វើយកទៅលក់មែនយាយ?

ខ៖ ធ្វើដេកយកទៅក្រាលហាលស្រូវហាលអីនឹងហាស

ក៖ ចឹងហោសយាយបាទ?

ខ៖ នៅស្រុកស្រែនឹងដែរមានស្អីទិញកន្ទេលអញ្ចឹតគេមួយៗនឹងអរចង់ស្លាប់ហើយនឹង

កៈ អូ៎!!បាទយាយបាទ
ចុះយាយអាចប្រាប់ពេលលំបាកតាំងពីក្មេងរហូតមកដល់ពេលនេះបានទេយាយ ថាយាយធ្លាប់មានការលំបាកអីគេខ្លះដែរចឹងហាសយាយ?

ខៈ ខ្ញុំគ្មានលំបាកអីទេធម្មតានឹងហាសទៅទីណាគេអោយហូបដែរនឹងខ្ញុំ

កៈ ចុះកាលពីក្មេងយាយគិតថាយាយធ្លាប់ជួបទុកលំបាកអីគេដែរទៅយាយ ដោយសារតែឪពុកម្ដាយយាយស្លាប់តាំងពីក្មេងចឹងហាស?

ខៈ មីងរបស់ខ្ញុំនឹងចិញ្ចឹមខ្ញុំអោយខ្ញុំមើលគោនឹងហាស

កៈ អូ៎!!យាយមើលតែគោទេណយាយ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះយាយជំនាន់អ៊ីសារ៉ាក់នឹងយាយទាន់ទេយាយ?

ខៈ ចឹមិនទាន់ណុងខ្ញុំអាយុ14ឆ្នាំហើយនឹង

កៈ ប៉ុន្តែយាយពេលណុងមានបញ្ហាអីគេខ្លះដែរទៅយាយ?

ខៈ ខ្ញុំអត់មានអីដែរនឹង

កៈ អូ៎!!នៅជំនាន់អ៊ីសារ៉ាក់គ្រាន់តែគេបាញ់គ្នាអីតែប៉ុណ្ណឹងទេណយាយ?

ខៈ គេបាញ់តែគេនឹងយើងមានទៅរវល់អីនឹងគេ

កៈ អូ៎!!បាទយាយត្រូវ?

ខៈ យើងទៅកើតទុកអីអោយតែមានអង្ករដាំបាយចឹងទៅបានហើយនឹង

កៈ សំខាន់អោយតែយើងមានអង្ករដាំបាយខ្លួនឯងណយាយ?

ខៈ ចា៎!!នឹងហើយអានឹងវាចឹងហោយ

កៈ ចុះនៅជំនាន់លុនណុលវិញយាយ?

ខៈ លុនណុលក៏ចឹងដែរអត់មានទាក់ទងគេអោយមានស្គាល់គ្នាអីទេនឹង បើទាក់ទងនឹងទាក់ទងអោយអង្ករខ្ញុំនឹងហាស

កៈ អ៎ូ!!ប៉ុន្តែអត់មានបញ្ហាអីដល់យាយទេណាយាយ?

ខៈ អត់មានទេ

កៈ ចុះជំនាន់ពលពតវិញយាយ?

ខៈ ពលពតនឹងក៏គេស្រួលដែរនឹងគេមកសំភាសន៍អីចឹងទៅធ្វើអីៗចឹងទៅ ខ្ញុំថាអើរហែងយកអញ់ទៅវៃចោលអោយហើយចឹងទៅ

កៈ ហាសចឹងហោសយាយ?

ខៈ វាបានសើចវាថាសុទ្ធតែគ្នាឯងនឹងគ្នាឯងអ្នកស្រុកឯងនឹង

កៈ អ៎ូ!!ប៉ុន្តែពេលណុងយាយអាយុប៉ុន្មានដែរយាយ?

ខៈ ខ្ញុំភ្លេចហើយខ្ញុំបានភ្លេចហើយនឹង

កៈ ប៉ុន្តែពេលណុងយាយមានគ្រួសារហើយណាយាយ?

ខៈ អត់ទេខ្ញុំមេម៉ាយរហូតនឹង

កៈ អ៎ូ!ចឹងហោសយាយ?

ខៈ ចុះប្តីរបស់ខ្ញុំនឹងស្លាប់តាំងពីឆ្នាំ1974មកនឹង

កៈ អ៎ូ!!បាទយាយបាទ?

ខៈ ហើយយកគាត់ទៅដុតនឹងមានបានកប់ណាចឹងបានកូនចៅរកស៊ីអត់មានមែនខ្ញុំក្តៅក្រហាយមែន ហើយខ្ញុំវាក្រពេកហោសមិនដឹងថាធ្វើយ៉ាងម៉េចក៏យកឆ្អឹងទៅទុកចោលនឹង

កៈ អ៎ូ!!ចឹងហោសយាយ?

ខៈ ហើយយើងរកស៊ីអត់មានទេគេចិនហោស

កៈ ប៉ុន្តែកាលពីជំនាន់ពលពតនឹងគេអោយយាយទៅណាគេអោយយាយនៅណា?

ខៈ នៅស្រុកណុងដដែលនឹង

កៈ អ៎ូ!!ចឹងហោសយាយ?

ខ៖ នៅស្រុកជ្រៃនឹងនរណាក៏ស្គាល់ដែរនឹងគេហៅខ្ញុំតែយាយសាក់បីនឹង

ក៖ គេហៅយាយសាក់បីហោសយាយ?

ខ៖ ខ្ញុំថានឹងធ្វើអោយអញ់ស្លាប់ហើយនឹងហាសអាប្រធានអីក៏វាហៅយាយសាក់បីនឹងដែរ

ក៖ អូ៎!!ចឹងហោសយាយបាទ?

ខ៖ អាប្រធានអីក៏វាហៅចឹង អាប្រធានពេងបាយក៏វាហៅ
អាប្រធានកងក៏វាហៅដែរយាយសាក់បីដូចជាមិនទាន់មកហី

ក៖ អូ៎!!បាទយាយ?

ខ៖ សុទ្ធតែចឹងទៅហេអាពួកនេះចង់សំលាប់អញ់ហើយមើលទៅ

ក៖ គេនិយាយលេងតើហីយាយ?

ខ៖ គេនិយាយលេងនឹងហាសចុះគ្មានឯងនឹង

ក៖ បាទយាយ ចុះពេលណុងពលពតគេអោយយាយធ្វើអីគេដែរទៅយាយ?

ខ៖ គេអោយស្ទូងដកដែរនឹង

ក៖ គេអោយស្ទូងដកហោសយាយ?

ខ៖ ចាំ!!ជូនណាអោយដេញចាបទៅនឹង ជូនណាអោយទៅបាចទឹកសំណាបចឹងទៅ

ក៖ ប៉ុន្តែពេលណុងយាយ?

ខ៖ ច្រូតក៏ខ្ញុំចេះ ចុះបើធ្លាប់ច្រូតពីក្មេងហើយនឹង

ក៖ ប៉ុន្តែពេលណុងយាយនៅកងនារីដែរណេតយាយ?

ខ៖ គេហៅការរដ្ឋានកណ្តាល

ក៖ គេហៅការរដ្ឋានកណ្តាលហោសយាយ?

ខ៖ នឹងហើយនឹង

កៈ ដោយសារតែពេលណុងយាយអាយុបច្រើនដែរហើយណាយាយ
យាយចាស់ដែរហើយណាយាយ?

ខៈ អើរចាស់ហើយនឹងហាស

កៈ អូ៎!!បាទយាយ?

ខៈ ត្បិតតែឃើញចឹងទេបាយហាសគេហូបបបរលាន់ ខ្ញុំហូបបាយហាស

កៈ អូ៎!!ចឹងហោសយាយ?

ខៈ ខ្ញុំទៅការរដ្ឋានកណ្ដាលវាពីរនាក់

កៈ អូ៎!!បាទយាយបាទ?

ខៈ វាអោយបាយមួយឆ្នាំងនឹងហាស

កៈ បាទយាយបាទ?

ខៈ មានពងទា មានត្រីងៀតនឹងដាក់មកអោយខ្ញុំនឹង

កៈ បាទយាយបាទនឹង?

ខៈ ល្ងាចបាននៅសល់បាយវេចអោយកូនដោយក្រម៉ានឹង

កៈ អូ៎!!ចឹងទេហោសយាយ?

ខៈ ហូបមិនអស់នឹងហាស

កៈ ចុះយាយបើ?

ខៈ កូនរបស់ខ្ញុំនឹងវានៅតូចនឹងមីមួយនឹងវាធំហើយប៉ុន្តែវាគេអោយវាខាងហាលអាចម៍

កៈ គេអោយហាលអាចម៍ហាសពេលណុងគាត់ក្លាយជាកងនារីហើយណាយាយ?

ខៈ ជាកងនារីហើយនឹង

កៈ ប៉ុន្តែពេលណុងគេអោយនៅជាមួយយាយហោសយាយ?

ខ៖ នៅជុំគ្នាទាំងអស់នឹងហាសគេធ្វើផ្ទះអោយនៅទៀតនឹង
អើរគេធ្វើតូចល្មម3ម៉ែត្រ4ជ្រុងអីចឹងទៅ

ក៖ ប៉ុន្តែពេលណុងនៅព្រៃវែងណាយាយ?

ខ៖ នៅព្រៃវែងនឹងនៅឃុំជ្រៃនឹងទៅស្រុកកំណើតស្រុកម៉ែឪនៅណុងមិនទៅ

ក៖ អូ៎!!បាទយាយាបាទចុះយាយគិតថា
រហូតដល់ពេលណាដែរយាយមកនៅភ្នំពេញហាសយាយ?

ខ៖
អើរវាបែកនឹងវាចេះតែចេញៗៗទៅនឹងចេញរៀងខ្លួននឹងអូមកនឹងមានអង្ករបីបួនប៉ាវហោស
គេអោយយើងច្រូតតាមចិត្តហោស

ក៖ ចឹងហោសយាយ?

ខ៖ ច្រូតបានអង្ករបួនប៉ាវនឹង

ក៖ ចឹងច្រូតបានបួនប៉ាវណាយាយ?

ខ៖ ដូលរទេះគេនឹងមកដល់អ្នកលឿងនឹងមកដូរមាសដូរអីបានពាក់នឹង

ក៖ អូ៎!!បាទយាយបាទ?

ខ៖ ចុះស៊ីមិនអស់នឹង

ក៖ បាទយាយដល់ពេលដែរជំនាន់ពលពតហើយពេលដែរដាច់ពលពតហើយ
ចូលជំនាន់ខ្មែរក្រហមមែនទេយាយរឺមួយក៏យ៉ាងម៉េចដែរ?

ខ៖ អត់ទេគ្មានខ្មែរក្រហមណាទៀតនឹង

ក៖ ខ្មែរក្រហមនឹងពលពតនឹងហើយណាយាយ?

ខ៖ នឹងហើយនឹង

ក៖ បាទចុះយាយ?

ខ៖ គ្មានខ្មែរក្រហមណាទៀតទេធូរសំបូរសប្បាយទៀតនឹងហាសស៊ីត្រីតែរហូតនឹងឆ្ងាញ់គ្រាន់បើជាងនៅស្រុកស្រែស៊ីក្តាមខ្យង់ដែរនឹង

ក៖ ហាសហាបាទយាយបាទ?

ខ៖ មកនឹងត្រីតែរហូតដៃរនឹងត្រីប៉ុនៗៗកំភ្លៅប៉ុនៗៗកំភួនជើងនឹង

ក៖ បាទមកពីណាដែរយាយ?

ខ៖ ចាំ!!ថាម៉េច?

ក៖ បានមកពីណាដែរយាយ?

ខ៖ នេះតាមស្រះតាមប្រឡាយនឹងហាស

ក៖ អូ្ហ!!បាទយាយបាទ
ចុះគិតថាយាយឆ្លងកាត់ការលំបាកមួយនឹងដោយរបៀបណាដែរយាយ?

ខ៖ អត់មានបាយទេវាសប្បាយនឹងស៊ីចុកនឹង

ក៖ អូ្ហ!!ចឹងហោសយាយហោស?

ខ៖ គ្មានពិបាកអីទេសប្បាយរហូតនឹង

ក៖
បាទចុះយាយគិតថាពេលណាដែរយាយគិតថាសប្បាយនៅក្នុងឆាកជីវិតរបស់យាយដែរចឹងហាស?

ខ៖ អើរសប្បាយតែរហូតនឹងហាសតែដល់មានកូនមានចៅហាត់បំរើវា

ក៖ អូ្ហ!!បាទយាយបាទ?

ខ៖ នឹងហើយទើបពិបាកពេលដែរចាស់នឹងនេះនឹង

ក៖ ចឹងទើបតែពិបាកពេលដែរចាស់នឹងទេហោសយាយ?

ខ៖ ចាំ!!នឹងហើយ

ក៖ ចុះយាយពិបាកអីគេដែរពេលចាស់នឹងហាសយាយ?

ខ៖ ពិបាកមើលចឹងហាសត្រូវដាក់ដាំបាយអោយកូនចៅទុកអោយវាតិចទៅមកហើយនឹង

ក៖ អូ៎!!គាត់មកពីធ្វើការងារវិញហោសយាយ?

ខ៖ អត់ទេវាទៅទិញស្អីមិញទៅតាំងពីព្រឹកហើយនឹង

ក៖ អូ៎!!ចឹងទេណាយាយណា?

ខ៖ ចា៎!!នឹងហើយចឹង

ក៖ បាទយាយ
ចុះយាយមានធ្លាប់គិតថាមានគោលបំណងថាពេលដែរធំឡើងនឹងយាយចង់ធ្វើអីគេទេ?

ខ៖ អត់អត់គិតទេ អត់គិតទេនឹងនៅតែជួយធ្វើគេស៊ីអោយឆ្អែតនឹង

ក៖ អូហ៎!!ជួយធ្វើគេហើយហូបមួយឆ្អែតទៅ?

ខ៖ ហូបមួយឆ្អែតនឹងហាស

ក៖ ជួយធ្វើអីគេដែរយាយ?

ខ៖ ដូចជាធ្វើម្ហូបធ្វើបន្លែអីចឹងហាសមើលឃើញគេលក់គេដូរអីជួយគេចឹងទៅ

ក៖ អូ៎!!ចឹងទេហោសយាយ?

ខ៖ គេអោយហូបមួយឆ្អែត គេអោយលុយចាយបន្តិចបន្តួចចឹងទៅណាស់

ក៖ ពេលឥឡូវនឹងវីមួយក៏ពីមុនហាសយាយ?

ខ៖ កាលពីមុននឹងហាសកាលពីមិនទាន់មានប្តីមានអីនឹង

ក៖ អូ៎!!ម៉េចចឹងពេលណុង?

ខ៖ ដល់ពេលដែរវាឃើញយើងពិបាកគេអាណិតគេស្រលាញ់យើង
យើងស្រលាញ់គេបានគ្នានឹង

ក៖ អូហូ!!ចុះហេតុអីបានជាយាយទៅជួយធ្វើការងារគេចឹង?

ខ៖ ចុះវាជិតគ្នានឹងឃើញគេធ្វើចឹងទៅទើសភ្នែកចឹង

កៈ បាទយាយបាទអ្នកភូមិជាមួយគ្នាដែរតើហីយាយ?

ខៈ នឹងហើយ

កៈ អូ៎!!បាទចុះយាយពេលណុងយាយចេះតែជួយធ្វើគេធម្មតាទេណយាយ?

ខៈ ជួយធ្វើធម្មតានឹងហាស

កៈ បាទយាយបាទ ចុះបើសិនជាចង់អោយយាយផ្តែផ្តាំទៅកូនចៅជំនាន់ក្រោយៗៗ តើយាយចង់ផ្តែផ្តាំអីទៅពួកគាត់ដែរយាយ?

ខៈ ចា៎!!មិនដឹងផ្តាំអីទេផ្តែផ្តាំអោយតែវាខំប្រឹងប្រែងរៀនសូត្រតែប៉ុណ្ណឹង

កៈ អូ៎!!បាទយាយបាទ?

ខៈ ចា៎!!នឹងហើយចឹង

កៈ ចុះមានអីផ្សេងទៀតទេយាយ?

ខៈ អោយវារៀនអោយចេះដឹងទៅការងារអីក៏គេយកដែរនឹង

កៈ បាទយាយបាទនឹង?

ខៈ ហើយខ្ញុំអត់ចេះសោះនឹងមួយអង្គក៏មិនចេះសោះ

កៈ ចឹងយាយមិនចេះអក្សរទេណយាយ?

ខៈ អត់ចេះទេ

កៈ បាទយាយបាទ?

ខៈ អត់ចេះអក្សរទេប៉ុន្តែចំណាប់ជាងគេអ្នកដែរចេះអក្សរទៀតនឹងហាស

កៈ អូ៎!!បាទយាយបាទ ចុះយាយមានអីចង់ផ្តែផ្តាំទៀតទេយាយ?

ខៈ អត់មានផ្តែផ្តាំអីទៀតទេមានតែផ្តែផ្តាំអោយកូនចៅជំនាន់ក្រោយនឹងអោយវារៀន

កៈ អូ៎!!អោយខំប្រឹងរៀនហោសយាយ?

ខៈ នឹងហើយចឹង

កៈ ចឹងមានតែប៉ុណ្ណឹងទេណយាយ?

ខៈ ចា៎!!នឹងហើយ

កៈ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនយាយ

ខៈ អោយដេកពីព្រឹកថ្ងៃឡើងនឹងយើងធ្វើនេះធ្វើនោះទៅណាស់

កៈ បាទយាយបាទនឹង?

ខៈ ហើយពេលដែរយើងចេះជ្រៅជ្រះទៅយើងចូលធ្វើការងារវាស្រួល

កៈ គេស្រួលទទួលយកយើងណយាយ?

ខៈ ចា៎!!នឹងហើយ

កៈ បាទយាយចុះ?

ខៈ ចុះខ្ញុំមានចៅណាមានចៅតែពីនឹងហើយវាសុទ្ធតែរៀនថ្នាក់ទី10ហោស

កៈ បាទយាយបាទ?

ខៈ ចា៎!!នឹងហើយ

កៈ ចុះបើសិនជាចង់អោយពួកគាត់ជៀសវៀងវិញហាសកូនចៅហាសយាយ
តើយាយចង់អោយពួកគាត់ជៀសវៀងអីគេដែរយាយ?

ខៈ អត់អីទេអត់មានអីទេចៅរបស់ខ្ញុំនឹងវាល្អជាទេ

កៈ ប៉ុន្តែចង់និយាយថាចង់អោយពួកគាត់ជៀសវៀងពីអំពើអត់ល្អចឹងហាស?

ខៈ អត់ទេងត់មានទេ

កៈ ដូចមានអីគេខ្លះដែរទៅយាយ?

ខៈ អត់មានអីទេចៅរបស់ខ្ញុំនឹងគិតថាខាងលេងភ្លេងនឹង

កៈ ប៉ុន្តែបើថារឿងគ្រឿងញៀនវិញយាយចង់អោយពួកគាត់ជៀសវៀងហាស?

ខ៖
ចុះមាននរណាគេហ៊ានថាអោយគេមកពិនិត្យទឹកនោមមើលបើសិនជាអត់សងជំងឺចិត្តខ្ញុំ

ក៖ អូ៎!!ប៉ុន្តែយាយចង់អោយពួកគាត់ជៀសវៀងទាំងអស់នឹងមែនទេយាយ?

ខ៖ ចា៎!!វាជៀសវៀងខ្លួនវានឹង

ក៖ អូ៎!!បាទយាយបាទ?

ខ៖ នេះៗៗនឹង

ក៖ អូ៎!!បាទចុះមានអីចង់ផ្តែផ្តាំទៀតទេយាយ?

ខ៖ អត់មានអីទេចង់អោយតែកូននឹងចេះដឹងនឹង

ក៖ អូ៎!!បាទយាយបាទ ចឹងមានតែប៉ុណ្ណឹងទេណាយាយ?

ខ៖ ចា៎!!នឹងហើយ

ក៖ ចឹងជាចុងក្រោយខ្ញុំអរគុណច្រើនយាយដែរបានអោយខ្ញុំពិភាក្សាជាមួយយាយ
ហើយនឹងបានអោយ
ខ្ញុំបានទុកប្រវត្តិរបស់យាយទុកអោយកូនចៅជំនាន់ក្រោយៗរបស់យាយបានស្គាល់នឹង
បានដឹងចឹងហាសយាយ

ខ៖ គេរកស៊ីមានៗៗហោសគេខំដាក់ទៀត

ក៖ បាទយាយបាទចឹងអរគុណច្រើនណាស់យាយ៕៕៕